# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ...៦១០.......ប្រក.កសក

## ប្រកាស
## ស្តីពី
## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

# សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពតសម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាព តាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះនិងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត នៃប្រកាសនេះមានបួន(៤) សហគមន៍ព្រៃឈើ ចែកចេញជាបួនកន្លែងដែលមានផ្ទៃដីសរុបចំនួន១៩៣៦ (មួយពាន់ប្រាំបួនរយសាមសិបប្រាំមួយ)ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និងផែនទីព្រៃសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះនិងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធនិងប្រធានមន្ទីរកសិកម្មខេត្តកំពត ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**ជ័ន្ទ សារុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពត
- ដូចប្រការ ៦

ឯកសារ-កាលប្បវត្តិ

# ផែនទីព្រៃសហគមន៍ភ្នំតូទឹប ឃុំស្រែជាខាងត្បូង ស្រុកដងទង់ ខេត្តកំពត

## Phnom Toteb Forestry Community Mapping Srea Chea khang Tboung Commune, Dang Tong District Kampot Province.



# ផែនទីព្រៃសហគមន៍ភ្នំគុបធ្យូង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត

**Phnom Kup Thyoung Forest Community Mapping Prey Thnong Commune Teuk Chhou District Kampot Province.**



# ផែនទីព្រៃសហគមន៍ភ្នំជ្រោះកង្កែប ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត

**Phnom Chup Kangkep Forest Community Mapping Prey khmum Commune Teuk Chhou District Kampot Province.**



# ផែនទីព្រៃសហគមន៍ព្រែកត្នោត ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត

## Prek Thnaot Forest Community Mapping Prek Thnaot Commune Teuk Chhou District Kampot Province.



**ឧបសម្ព័ន្ធ ២** ៖ភ្ជាប់ប្រកាសលេខ ...៦១០ ប្រ.ក.កសក...ចុះថ្ងៃទី ..០៥.....ខែ ..ធ្នូ..........ឆ្នាំ..២០១១.......

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពត

| លរ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកា ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ភ្នំទទឹប | ៧៦៣ | 433162-1174803<br>433146-1174799<br>432947-1174766<br>432824-1174748<br>432581-1174693<br>**A433771-1177977**<br>431665-1177013 | 431901-1177717<br>432080-1177580<br>432404-1177554<br>432742-1177686<br>432991-1177788<br>433563-1177962<br>**B434890-1175467** | 434272-1177146<br>434241-1176971<br>434158-1176936<br>434109-1176763<br>434765-1176504<br>435075-1176072<br>**C432499-1174674** | 434586-1175360<br>434184-1175189<br>433802-1174998<br>433196-1174861<br>433162-1174803<br>431979-1177152<br>**D431576-1177644** | ៣ | ស្រែជាខាងត្បូង | ជងទង់ | កែប |
| ២ | ភ្នំគុបព្យូង | ១៦១ | 423556-1186283<br>423573-1186067<br>423615-1185905<br>423646-1185547<br>**A422930-1185905**<br>423719-1185388<br>423753-1185288<br>423792-1185177<br>423854-1185051<br>423211-1186563<br>423295-1186488<br>423420-1186466 | 423892-1184944<br>423871-1184846<br>423845-1184750<br>423831-1184655<br>423791-1184559<br>423701-1184429<br>**B423772-1185496**<br>423547-1184465<br>423005-1185695<br>**C423613-1184399**<br>**D422935-1185805**<br>423556-1186283 | 423493-1184533<br>423447-1184618<br>423385-1184702<br>423342-1184796<br>423340-1184937<br>423297-1185038<br>423280-1185145<br>423248-1185260<br>423214-1185354<br>423105-1185626<br>423115-1186606<br>423493-1186384 | 422940-1185999<br>422964-1186103<br>422927-1186208<br>422860-1186285<br>422830-1186379<br>422789-1186463<br>422764-1186571<br>422760-1186671<br>422830-1186717<br>422933-1186690<br>423029-1186659 | ១ | ព្រៃថ្នង | ទឹកឈូ | កែប |
| ៣ | ជ្រោះកង្កែប | ៨៥ | **A412461-1183809**<br>412672-1183754<br>412905-1183761<br>412461-1183809 | **B413878-1182457**<br>413457-1182727<br>413201-1182926<br>**D412110-1183734** | 413217-1183268<br>413073-1183104<br>413044-1182963 | 412804-1182961<br>**C412409-1182998**<br>412214-1183261 | ២ | ព្រៃឃ្មុំ | ទឹកឈូ | កែប |

| លរ | ឈ្មោះសហគមន៍ ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកា ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះ ឃុំ | ឈ្មោះ ស្រុក | ផ្នែករដ្ឋបាល ព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | ព្រៃកន្ទោត | ១.០០៧ | 388712-1171031<br>389846-1170748<br>391192-1170994<br>**A384045-1174392**<br>392836-1170831<br>392796-1170722<br>392754-1170663<br>392696-1170607<br>392664-1170576<br>392635-1170456 | 392652-1170242<br>392574-1170158<br>392488-1170123<br>392394-1170067<br>392341-1169969<br>392297-1169854<br>392231-1169754<br>392146-1169680<br>392099-1169610<br>392652-1170347 | 392057-1169525<br>392060-1169412<br>392050-1169358<br>392023-1169269<br>391996-1169233<br>391925-1169185<br>391818-1169136<br>391772-1169122<br>391709-1169119<br>391661-1169100 | 390328-1169442<br>389020-1169876<br>387500-1170508<br>**B392841-1170898**<br>**C391633-1169041**<br>387278-1171618<br>387600-1171464<br>388712-1171031<br>**D383956-1173455** | ៤ | ព្រៃកន្ទោត | ទឹកឈូ | កែប |
| សរុប | | ១.៩៣៦ | | | | | ១០ | ០៤ | ០២ | ០១ |